# មជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជា ចេញរបាយការណ៍ ស្តីពីការបង្ក្រាប ទៅលើសេរីភាព កម្ពុជានៅតែបន្ត

Monday, 13 June 2011 19:18 eday³ eGg KwmCag

**ភ្នំពេញ :** នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានចេញផ្សាយ កំណត់ត្រា សង្ខេបមួយ ដែលមានចំណង ជើងថា ការគាបសង្កត់លើ ប្រព័ន្ធអ៊ិនធើណែត "ការបង្ក្រាបទៅលើ សេរីភាពបញ្ចេញមតិ នៅកម្ពុជានៅតែបន្ត" ។

ប្រធានមជ្ឈមណ្ឌល សិទ្ធិមនុស្សកម្ពុជា លោក អ៊ូ វីរៈ មានប្រសាសន៍ ប្រាប់មជ្ឈមណ្ឌល ព័ត៌មាន ដើមអម្ពិល នៅរសៀលថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១នេះ ថាការបញ្ចេញ របាយការណ៍មួយនេះ ដើម្បីចង់បង្ហាញ សិទ្ធិទទួលព័ត៌មាន និងបញ្ចេញមតិ នៅតាមប្រព័ន្ធ អ៊ិនធឺណែតនៅកម្ពុជា ដែលកំពុងតែមាន បញ្ហាប្រឈមមួយចំនួន ដែលជាប់ពាក់ព័ន្ធ តំលៃអ៊ិនធឺណែត និងប្រជាពលរដ្ឋ ចូលរួមក្នុងប្រព័ន្ធ អ៊ិនធឺណែត មានចំនួនតិច នៅឡើយ ព្រមទាំងបាន លើកឡើងពីបញ្ហា គាបសង្កត់មួយចំនួន ទាក់ទង និងការបិទវេបសាយ ការចាប់ខ្លួន អ្នកប្រើប្រាស់ថ្វីនធឺ ការចាប់អ្នកខ្លួនថត ចំលងអត្ថបទតាម អ៊ិនធឺណែត ដែលជាការ គំរាមកំហែង ទៅលើអ្នកប្រើប្រាស់ ប្រព័ន្ធអ៊ិនធឺណែតសព្វថ្ងៃនេះ។

លោកបញ្ជាក់ថា "មជ្ឈមណ្ឌល បានចេញរបាយការណ៍ ខ្លីមួយនេះ ទាក់ទងសិទ្ធិទទួលព័ត៌មាន និងសិទ្ធិបញ្ចេញ មតិនៅតាមប្រព័ន្ធអ៊ីនធឺណែត នៅក្នុងប្រទេសកម្ពុជា ក្នុងនោះយើងបាន លើកបញ្ហាប្រឈម មួយចំនួន ទាក់ទងរឿងតំលៃ នៃអ៊ិនធឺណែត ប្រជាពលរដ្ឋអ្នកចូលរួមប្រព័ន្ធ អ៊ិនធឺណែតមាន តិច ហើយយើងបាន លើកពីបញ្ហាគាបសង្កត់មួយចំនួន ទាក់ទងការបិទប្លុកស្លុត និងវេបសាយផ្សេងទៀត" ។

ទាក់ទងនិងបញ្ហានេះ មន្ត្រីរាជរដ្ឋាភិបាលបាន បដិសេធន៍ មិនធ្វើអធិប្បាយ លើរឿងនេះទេ ។

សេចក្តីថ្លែងការណ៍របស់ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានចេញផ្សាយនៅទី១៣ ខែមិថុនា ឆ្នាំ២០១១នេះបានឱ្យដឹងថា កាលពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១ នៅទីក្រុង ប៊ុយដាប៉េស្តិ៍បាន ចេញផ្សាយ សេរីភាពបញ្ចេញមតិ និងអ៊ិនធឺណែត ស្តីពី សេរីភាពទស្សនៈ និងបញ្ចេញមតិ ដោយអ្នកតំណាង ជំនាញបួនរូប របស់អ្នករាយការណ៍ ពិសេសអង្គការសហប្រជាជាតិ ។